# ព្រះរាជក្រឹត្យ

នស/រកត/១១១៧/១០៩៥

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិគស្តុភារកម្ម

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជ្យរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

# ត្រាស់បង្គាប់

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើតក្រុមប្រឹក្សាជាតិភស្តុភារកម្ម ដែលសរសេរជាអក្សរកាត់ថា **ក.ជ.ភ.** ជាសេនាធិការឱ្យរាជរដ្ឋាភិបាល ដើម្បីដឹកនាំ គ្រប់គ្រង និងជំរុញការអភិវឌ្ឍវិស័យភស្តុភារកម្មនៃព្រះរាជាណាចក្រកម្ពុជា។

ភស្តុភារកម្ម សំដៅដល់ការរួមបញ្ចូលគ្នាក្នុងការរៀបចំបែបបទ ការចាត់ចែង ការសម្របសម្រួល និងការអភិវឌ្ឍ ធាតុសំខាន់ដូចខាងក្រោម៖

១- ប្រព័ន្ធសម្របសម្រួល បែបបទទំនិញចេញ ចូល និងការដឹកជញ្ជូនឆ្លងកាត់ព្រំដែន។

២- ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូននិងពាណិជ្ជកម្ម មានជាអាទិ៍ ផ្លូវគោក ផ្លូវដែក ផ្លូវសមុទ្រ ផ្លូវទឹក ផ្លូវអាកាស កំពង់ផែ។

៣- សមត្ថភាពនិងគុណភាពនៃស្ថាប័នផ្តល់សេវាភស្តុភារកម្ម មានជាអាទិ៍ ស្ថាប័នដែលពាក់ព័ន្ធនឹងការធ្វើចរាចរណ៍ ការទុកដាក់ ការចែកចាយ និងការឆ្លងកាត់ទំនិញ។

៤- ការផ្តល់សេវាភស្តុភារកម្មទាន់ពេលវេលានិងប្រកបដោយទំនុកចិត្ត។

៥- ភាពងាយស្រួលក្នុងការដឹកជញ្ជូនទំនិញប្រកបដោយតម្លៃប្រកួតប្រជែងទៅទីផ្សារអន្តរជាតិ។

៦- ប្រព័ន្ធព័ត៌មានតាមដានរំហូរនៃការដឹកជញ្ជូនទំនិញនិងអ្នកដំណើរ។

## ជំពូកទី២

## សមាសភាពរបស់ ក.ជ.ភ.

**មាត្រា២ .-**

**ក.ជ.ភ.** មានសមាសភាព ដូចខាងក្រោម៖

- ឧបនាយករដ្ឋមន្ត្រី ១រូប ប្រធាន
- រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន អនុប្រធានប្រចាំការ
- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធាន

- រដ្ឋមន្ត្រីក្រសួងផែនការ សមាជិក
- រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម សមាជិក
- អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក
- អគ្គលេខាធិការឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ សមាជិក។

**ក.ជ.ត.** អាចមានសមាសភាពបន្ថែម តាមការចាំបាច់។

សមាសភាពជាក់ស្តែងរបស់ **ក.ជ.ត.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជ-រដ្ឋាភិបាល។

## ជំពូកទី៣
## តួនាទីនិងភារកិច្ចរបស់ ក.ជ.ត.

**មាត្រា៣ .-**

**ក.ជ.ត.** មានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

- ផ្តល់គោលការណ៍ណែនាំ ក្នុងការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ផែនការមេ ផែនការសកម្មភាព និងលិខិតបទដ្ឋានគតិយុត្ត ក្នុងការគ្រប់គ្រងប្រតិបត្តិ និងអភិវឌ្ឍវិស័យភស្តុភារកម្មនៃព្រះរាជាណាចក្រកម្ពុជា
- សម្របសម្រួលនិងត្រួតពិនិត្យចុងក្រោយ នូវយុទ្ធសាស្ត្រ ផែនការមេ ផែនការសកម្មភាព និងលិខិតបទដ្ឋានគតិយុត្តវិស័យភស្តុភារកម្ម មុននឹងដាក់ជូនរាជរដ្ឋាភិបាលពិនិត្យនិងសម្រេច
- កំណត់អាទិភាពការអភិវឌ្ឍវិស័យភស្តុភារកម្ម រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង
- កៀរគរការគាំទ្រធនធានហិរញ្ញវត្ថុ បច្ចេកទេស និងធនធានមនុស្ស ដែលជាតម្រូវការចាំបាច់ ដើម្បីជំរុញការអភិវឌ្ឍវិស័យភស្តុភារកម្ម
- ត្រួតពិនិត្យការអនុវត្តការងារ និងផ្តល់អនុសាសន៍ណែនាំ ដើម្បីដោះស្រាយបញ្ហានានានៅក្នុងវិស័យភស្តុភារកម្ម
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលរាជរដ្ឋាភិបាលប្រគល់ជូន។